# មរតកអសកម្មខ្លះ
# ដែលអាចទទួលឥទ្ធិពលពីសុភាសិតខ្មែរ

ខ្មែរយើងជាសាសន៍មួយដែលមានទេពកោសល្យខាងសិល្បៈ និងការច្នៃប្រឌិត។ អ្វីដែលគួរសង្កេតឃើញក្រៅអំពីរចនាបទខាងសំណង់ស្ថាបត្យកម្ម យើងមានកំរងកំណាព្យ អក្សរសាស្ត្រ អក្សរសិល្ប៍ និងសុភាសិតបុរាណជាច្រើន។ ជាពិសេសសុភាសិតបុរាណដែលជាសំនួនក្លែមពាក្យ ដោយយករឿងរ៉ាវដែលត្រូវអធិប្បាយវែង មកបំព្រួញនិយាយតែពីរបីម៉ាត់ ដែលធ្វើឱ្យអ្នកស្តាប់អាចយល់ន័យបាន។

សុភាសិតខ្លីៗទាំងអស់នោះ មានដេរដាសទាំងក្នុងបរិបទសង្គម សេដ្ឋកិច្ច នយោបាយ វប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈកំសាន្ត និងប្រលោមលោក ជាដើម។ ដូចដែលយើងធ្លាប់បានដឹង និងមានការធ្វើការវិភាគនិទស្សន៍ទៅលើសុភាសិតទាំងអស់នោះ ឃើញថាសុភាសិតខ្លះមានប្រយោជន៍និងសកម្មជួយលើកស្ទួយសង្គមខ្មែរយើងឱ្យឡើងខ្ពស់ ប៉ុន្តែសុភាសិតខ្លះនាំមកជាមួយតែតំហយភាពតែប៉ុណ្ណោះ។ ពិតណាស់ថាសុភាសិតបុរាណទាំងអស់នោះខ្លះអាចមានតំលៃខាងប្រវត្តិសាស្ត្រ តែវាជាតួហេតុមួយយ៉ាងសំខាន់ដែលបន្ទុចបង្អាក់ការព្យាយាម ការតស៊ូ និងការរើបំរាស់របស់ខ្មែរយើង។ យើងក៏គួរកត់សំគាល់ដែរថាបំណងនៃអ្នកបង្កើតសុភាសិតខ្លះមិនបានមានចេតនាបន្ទុចបង្អាក់ទេ តែពេលគេយកទៅប្រើបន្តិចម្តងៗវាបានក្លាយទៅជាគំនិតមិនជឿនលឿនទៅវិញ។ ក្នុងចំណោមសុភាសិតទាំងអស់នោះ សុភាសិតដែលកើតចេញពីពាក្យអ្នកស្រុកពីមួយទៅមួយតែងតែមានភាពអវិជ្ជមាននៅក្នុងតថភាពជាក់ស្តែងនៃសង្គម។

សុភាសិតខ្មែរយើងភាគច្រើនមានលក្ខណៈជាសេចក្តីពិតតាមធម្មជាតិសុទ្ធសាធ ប៉ុន្តែយើងត្រូវដឹងថាការនិយាយឱ្យពីរោះតាមលក្ខណៈធម្មជាតិសុទ្ធសាធទាំងអស់នោះ មិនអាចធានាដល់តថភាពជាក់ស្តែងរបស់សង្គមបានឡើយ ជាពិសេសក្នុងការយកមកអប់រំកូនចៅរបស់ខ្មែរយើង។

តទៅនេះសូមលើកយកសុភាសិតមួយចំនួនដែលខ្មែរយើងគ្រប់គ្នាចេះ និងតែងតែយកមកនិយាយតមាត់គ្នា ដែលការនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើស្រទាប់នៃផ្នត់សង្គមខ្មែរ។

## យុវជនជាទំពាំងស្នងឫស្សី

សុភាសិតនេះ នរណាក៏ចេះដែរនៅក្នុងស្រទាប់សង្គមខ្មែរ ជាពិសេសអ្នកផ្តល់ការអប់រំ និងក្នុងចំណោមសិស្សនិស្សិតបញ្ញវន្ត។ មែនទែនទៅសុភាសិតនេះគឺពីរោះណាស់សំរាប់ពញ្ញាក់ស្មារតីយុវជនឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ក៏ដូចជាយកចិត្តដាក់រឿងប្រទេសជាតិរបស់ខ្លួន។ ប៉ុន្តែបើផ្អែកទៅលើតថភាពជាក់ស្តែងរបស់សង្គមខ្មែរយើង សុភាសិតនេះឆ្លុះបញ្ចាំងន័យអសកម្មពីរយ៉ាងយ៉ាងតិច។

១. ផ្ទុះបញ្ហាំងអំពីវប្បធម៌ចាស់និយម ដែលការអប់រំក្រៅប្រព័ន្ធរបស់ខ្មែរភាគច្រើន រមែងស្តីបន្ទោស ឬដាក់ធុរៈទៅលើក្មេងៗថា ជាអ្នកកើតមិនទាន់ចាស់ ឃើញព្រះអាទិត្យមិនទាន់ចាស់ បើចាស់ប្រាប់អ្វីត្រូវធ្វើតាម កុំចេះជាងចាស់ ត្រូវស្តាប់បង្គាប់ចាស់ដែលជាអ្នកចេះដឹងជាងខ្លួនជាដើម។ វប្បធម៌បែបនេះមានពាសពេញដេរដាស ចាប់តាំងពីឪពុកម្តាយ រហូតដល់ថ្នាក់ដឹកនាំជាតិ។ ភាគច្រើនអ្នកទាំងនេះច្រើនប្រើឥទ្ធិពលរបស់ខ្លួនគ្របសង្កត់ក្មេងមិនឱ្យគិតនូវអ្វីដែលគេចង់គិត មិនឱ្យធ្វើនូវអ្វីដែលគេចង់ធ្វើ។ ឪពុកម្តាយច្រើនអប់រំកូនឱ្យដើរតាមគន្លងធម៌ដែលគន្លងធម៌នេះមិនមែនធម៌ទេគឺពួកគាត់នោះឯង ចំណែកថ្នាក់ដឹកនាំវិញច្រើនតែអួតខ្លួនឯងថាពូកែ មិនចង់ប្រគល់តំណែងឬអំណាចឱ្យក្មេងធ្វើការឡើយ។ ការអប់រំដែលសង្កត់ធ្ងន់ទៅលើចាស់និយមបែបនេះ មិនអាចធានាដល់ការរីកចំរើនដល់យុវជនខ្មែរជំនាន់ក្រោយបានឡើយ ហើយក៏មិនត្រឹមត្រូវទៅតាមលទ្ធិព្រះពុទ្ធសាសនាដែលលើកតំកើងមនុស្សឱ្យចេះសំរេចចិត្តនិងមានខ្លួនឯងជាទីពឹង។ ការគិតរបស់ក្មេងតែងតែមានខុសនិងត្រូវ មិនខុសពីចាស់ដែរ ប៉ុន្តែការខុសនិងត្រូវរបស់ក្មេងនោះគឺជាមេរៀនដ៏មានតំលៃសំរាប់ពួកគេនាពេលអនាគត។ ក្នុងលក្ខណៈនេះហើយ ដែលសុភាសិតថាយុវជន ជាទំពាំងស្នងឫស្សីគឺពិតជាបបួលយុវជនឱ្យធ្វើល្អតែម្នាក់ឯង ដោយចាស់ៗទុកខ្លួនឯងថាជាអ្នកល្អត្រឹមត្រូវរួចទៅហើយ។

២. តាមធាតុពិតនៃដើមឫស្សី គឺពិតជាត្រូវការឱ្យមានទំពាំងលូតលាស់ឡើងស្នងដើមចាស់ដែលស្លាប់ទៅរបស់ខ្លួន។ ក៏ប៉ុន្តែយើងត្រូវដឹងថា បើដើមឫស្សីវាស្អុយថ្នាំង វាក្រៀមស្វិត ឬវាងាប់ចុងពុកគល់ តើវាអាចជាអំណោយផលល្អឱ្យទំពាំងលូតលាស់បានល្អបែបណា?។ នេះជាន័យសំខាន់ដែលថា បើចាស់ៗនោះមិនដែលអប់រំខ្លួនឯង ឬធ្វើខ្លួនឯងឱ្យបានល្អសំរាប់ជាគំរូផងតើធ្វើឱ្យក្មេងៗកូនចៅជំនាន់ក្រោយលូតលាស់បានល្អយ៉ាងណា?។ ដូច្នេះ សុភាសិតថា***ទំពាំងស្នងឫស្សី***គួរប្តូរមកជា***ទំពាំងអាស្រ័យដើមឫស្សី*** ទើបស័ក្តិសមជាង ព្រោះថាក្មេងជំទង់ជំនាន់ក្រោយពួកគេរៀនសូត្រទាំងស្រុងពីសំណាក់ឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ និងមេដឹកនាំជាតិរបស់ខ្លួន។ ចាស់ៗទាំងអស់នោះឬមេដឹកនាំទាំងអស់នោះ ត្រូវតែទទួលស្គាល់សេចក្តីពិតថាសង្គមប្រឫកច្របល់ ប្រទេសជាតិលិចលង់មិនមែនបណ្តាលមកពីពួកក្មេងៗទាំងអស់នោះទេ ហើយចាស់ៗ ទាំងអស់នោះមិនត្រូវស្តីបន្ទោសគ្នាយករួចខ្លួនតែរៀងៗខ្លួន មិនមានទំនួលខុសត្រូវហើយដាក់កំហុសមកលើក្មេងដែរ។

*ក្មេងៗមិនមែនជាផលិតផល ដែលសំរាប់តែចាស់ៗធ្វើអាជីវកម្មទេ*

## ខ្លួនទាបកុំតោង ដៃខ្លីកុំឈង ស្រវាអោបភ្នំ

នេះជាសុភាសិតខ្មែរមួយទៀត ដែលស្រង់យកសភាពពិតនៃធម្មជាតិទាំងស្រុងមកនិយាយប្រាប់គ្នាៗ ប៉ុន្តែសុភាពសិតនេះមិនមានផលល្អអ្វីសោះសំរាប់យកមកអប់រំយុវជនខ្មែរយើងជំនាន់ក្រោយ។ ពាក្យមួយម៉ាត់នេះ គឺបន្ទុចបង្អាក់មនុស្សមិនឱ្យមានការប្រឹងប្រែងយកឈ្នះលើការទន់ទាបរបស់ខ្លួន តែមានលក្ខណះជាការបង្រៀនឱ្យមនុស្សទទួលយកសភាពអ្វីដែលខ្លួនមានដោយមិនចាំបាច់ប្រណាំងប្រជែងជាមួយនឹងគេឡើយ។ សង្គមបច្ចុប្បន្នគឺជាសង្គមប្រកួតប្រជែងគ្នា បើខ្លួនខ្សោយខ្លួនអន់ហើយមិនខំប្រឹងប្រែងស្វះស្វាររនោះទេ យើងច្បាស់ជាបន្តភាពល្ងង់ខ្លៅ ក្រីក្រ និងស្ថិតក្រោមការគ្រប់គ្រង ឬឥទ្ធិពលរបស់អ្នកដទៃជាក់ជាមិនខាន។

ព្រះពុទ្ធជាម្ចាស់បង្រៀនយើងថា*ចូរអ្នកខំប្រឹងប្រែងដើម្បីរំដោះឱ្យចេញផុតពីសេចក្តីទុក្ខទាំងពួង វីរិយេនទុក្ខមច្ចេតិ* ឬអ្នកកុំប្រមាថក្នុងជីវិត ក៏ព្រោះតែសំគាល់ថាខ្លួនអន់ ខ្លួនល្ងង់ ខ្លួនមិនស្អាត មិនល្អ ឬមានបានដូចគេ ជាដើម។ មនុស្សក្នុងលោកកើតមកមានបញ្ញាស្មារតី ការតស៊ូព្យាយាម សិទ្ធិសេរីភាពដូចៗគ្នា គ្មាននរណាខ្ពស់ជាងនរណាទេ បើយើងមានការព្យាយាម។

សុភាសិតខ្មែរមួយនេះ ពិតជាបន្ទុចបង្អាក់មនុស្សម្នាក់មិនឱ្យមានការតស៊ូ ការព្យាយាមឡើយ។ ពិតតែសុភាសិតនេះសំដៅទាំងស្រុងទៅលើរឿងស្នេហានិងការរើសគូស្រករក៏ដោយ ក៏បរិបទសង្គមរបស់វាមិនអំណោយផលល្អទាល់តែសោះ។

ទន្ទឹមនឹងនេះដែរ ក៏មានវណ្ណកម្មខ្មែរយើងជាច្រើនដែលប្រឆាំងនឹងទស្សន:សុភាសិតនេះ ដូចជារឿងកូឡាបប៉ៃលិន និពន្ធដោយញ៉ុក ថែម បានលើកតំកើងបុរសកំសត់ កូនកំព្រាចោរចិត្តឱ្យឡើងកាន់ទ្រនំជាកូនប្រសាររបស់មហាសេដ្ឋីប៉ៃលិនបាន។

សុភាសិតនេះ គួរតែប្តូរទៅជា *ខ្លួនទាបខំតោង ដៃខ្លីខំឈង ស្រវាអោបភ្នំ* ទើបសមរម្យជាង

## ងើបស្កក អោនដាក់គ្រាប់

សុភាសិតនេះ មានប្រជាប្រិយ៍យ៉ាងខ្លាំងក្នុងស្រទាប់សង្គមខ្មែរ ហើយត្រូវបានមនុស្សភាគច្រើនជឿនិងបដិបត្តិតាមសុភាសិតមួយនេះ។ តាមលក្ខណះសេចក្តីពិតនៃធម្មជាតិគឺត្រឹមត្រូវសំរាប់សុភាសិតនេះ ប៉ុន្តែតាមតថភាពជាក់ស្តែងនៃសង្គមគឺត្រឹមត្រូវសំរាប់តែយុគទេវរាជាឬសម្បូរណាញាត្តិសិទ្ធិរាជ ឬយុគការដឹកនាំងផ្តាច់ការ ដែលអំណាចប្រមូលផ្តុំនៅកណ្តាល ដែលយើងនិយមហៅថាវិសហមជ្ឈិការ។ សព្វថ្ងៃនេះជាយុគលោកាភិវឌ្ឍន៍ សេដ្ឋកិច្ចទីផ្សារសេរី សកលភាវូបនីយកម្ម និងទំនើបកម្មខាងពត៌មានវិទ្យា។ ជាយុគនៃលទ្ធិប្រជាធិបតេយ្យសេរី ការគោរពសិទ្ធមនុស្ស ការអភិវឌ្ឍន៍ និងវិមជ្ឈិការ។ ការនេះជារបត់សង្គម

មួយដែលមិនចាំបាច់ក្រាបទូល អោនលំទោន បក្ខានុគ្រោះ ខ្សែញាតិសន្តាន និងសម្បទានឡើយ។ អ្វីគ្រប់បែបយ៉ាងត្រូវសំរេចចិត្តនិងធ្វើឡើងតាមរយះផ្លូវច្បាប់ សមភាព តម្លាភាព និងមិនរើសអើង។ ព្រះពុទ្ធជាម្ចាស់បានសង្កត់ធ្ងន់ទៅលើធម៌ឬប្រព័ន្ធច្បាប់នេះឯង។

សុភាសិតនេះមានគុណតំលៃដ៏តូចមួយសំរាប់វប្បធម៌ការគោរព ការដឹងគុណ និងការអោនលំទោនរបស់ខ្មែរ។ ដែលការប្រព្រឹត្តបដិបត្តិនេះអាចរាលដាលរហូតដល់សំងំរស់នៅឱ្យគេគ្រប់គ្រងយ៉ាងងាយស្រួលមិនចាំបាច់រើបំរាស់ទេ បើគេឱ្យយើងសុខ បើគេឱ្យយើងស្ងប់។

យើងសង្កេតឃើញថាផលល្អសំរាប់តំលៃខាងសង្គមមានតិចតួចណាស់ បើយើងប្រៀបធៀបទៅនឹងការបន្ទុចបង្អាក់ ការបាត់បង់ និងមហន្តរាយដែលអាចកើតចេញពីសុភាសិតដ៏មានប្រជាប្រិយ៍មួយនេះ។

ដូច្នេះសុភាសិតនេះ គួរត្រូវបានគេយកពិភាក្សាដោះស្រាយឱ្យបានទូលំទូលាយទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ សុភាសិតនេះ គួរប្តូរទៅជា ***ងើបរឹងប៉ឹង អោនដាក់គ្រាប់*** ។

## ហ៊ានស្បែកដាច ខ្លាចស្បែកស្វិត

នេះជាសុភាសិតមួយទៀតឆ្លុះបញ្ចាំងពីការសន្សំសុខក្នុងកាលៈទេសៈសង្គ្រាម ដោយបន្ទុចបង្អាក់កូនចៅរបស់គាត់មិនឱ្យក្លាហានទេ ដើម្បីឱ្យបានរស់នៅជួយជុំគ្រួសារ។ ការជួបជុំគ្រួសារនិងសេចក្តីរស់រានមានជីវិតគឺជាបំណងតែមួយគត់របស់មនុស្ស ដែលសារនេះបានលួងលោមមនុស្សឱ្យខំរស់ក្នុងស្ថានភាពបែបណាក៏ដោយ ឱ្យតែខ្លួនគេមានជីវិត។

សង្គ្រាមរបស់ខ្មែរយើង ជាសង្គ្រាមមហាវិនាសកម្មព្រោះជាការច្បាំងគ្នាឯង និងការលុកទន្ទ្រានពីសំណាក់បរទេស។

មានសុភាសិតខ្មែរជាច្រើនទៀត ដែលមានឥទ្ធិពលអាក្រក់នៅក្នុងសង្គមទាំងផ្នែកការអភិវឌ្ឍន៍ ការអប់រំ និងការកែច្នៃប្រទេសជាតិឈានទៅរកយុគថ្មី។